ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/ ៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃអគ្គនាយកដ្ឋាន...

ផែនការនិងស្ថិតិនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់នូវការបង្កើតឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម សម្រាប់បំពេញការងារអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងថ្នាំកសិកម្មនិងជីកសិកម្ម នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិនេះ ត្រូវបានអនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម រួមមានមន្ត្រីដែលបម្រើការងារនៅនាយកដ្ឋាននីតិកម្មកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រើសម្រាប់៖

១- បំពេញបេសកកម្មពាក់ព័ន្ធនឹងការងារអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម។

២- ចូលរួមសវនាការនៅតុលាការ។

៣- ចូលរួមពិធីផ្លូវការផ្សេងៗ។

## ជំពូកទី២

## ឯកសណ្ឋាន

**មាត្រា៣ .-**

ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម មានដូចខាងក្រោម៖

១- សម្លៀកបំពាក់(អាវ ខោ និងសំពត់)។

២- មួក។

៣- ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើង។

**មាត្រា៤ .-**

សម្លៀកបំពាក់របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មត្រូវបានកំណត់យកប្រភេទសាច់ក្រណាត់ពណ៌កាគីខ្ចី ដូចខាងក្រោម៖

**១- ថ្នាក់ដឹកនាំនាយកដ្ឋាន មន្ទីរ និងការិយាល័យ**

១.១- ចំពោះបុរស

- អាវដៃខ្លី កបើក ប៉ូលស្មាសងខាង ផែកខ្នង មានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន ៥(ប្រាំ)គ្រាប់ និងមានហោប៉ៅបួន ហោប៉ៅពីរខាងលើដេរបត់កណ្តាលគម្របរាងស្លឹកពោធិ៍ ហោប៉ៅពីរខាងក្រោមគ្មានផ្នត់កណ្តាល គម្របរាងចតុកោណកែង និងមានឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន៤(បួន)គ្រាប់
- ខោជើងវែងដេរអំពីសាច់ក្រណាត់ និងពណ៌ដូចអាវ ចង្កេះដេរត ថ្នេរបង្កប់ជីបភ្លីខាងមុខពីរ មានហោប៉ៅបួន ហោប៉ៅខាងក្រោយពីរដេរបង្កប់ គម្របរាងស្លឹកពោធិ៍ និងហោប៉ៅពីរទៀតនៅចំហៀងដេរបង្កប់តាមថ្នេរ។

១.២- ចំពោះស្ត្រី

- អាវដូចបុរស តែម៉ូតអាវរាងស្ត្រី
- សំពត់ខ្លី មានសាច់ក្រណាត់ និងពណ៌ដូចអាវកាត់ស្រុងក្រោមជង្គង់ ផែកក្រោយ រូតខាងក្រោយ ឬខោម៉ូតដូចបុរស តែគ្មានហោប៉ៅក្រោយ។

**២- ថ្នាក់មន្ត្រី**

២.១- ចំពោះបុរស

- អាវដៃវែង កឌុប ប៉ូលស្មាសងខាង ហោប៉ៅពីរដេរបត់ផ្នត់កណ្តាលគម្របរាងស្លឹកពោធិ៍ កាត់ស្រុងជើងត្រង់ដាក់ក្នុងខោ
- ខោជើងវែងដេរអំពីសាច់ក្រណាត់ និងពណ៌ដូចអាវ ចង្កេះដេរត ថ្នេរបង្កប់ជីបភ្លីខាងមុខពីរ មានហោប៉ៅបួន ហោប៉ៅខាងក្រោយពីរដេរបង្កប់ គម្របរាងស្លឹកពោធិ៍ និងហោប៉ៅពីរទៀតនៅចំហៀងដេរបង្កប់តាមថ្នេរ។

២.២- ចំពោះស្ត្រី

- អាវដូចបុរស តែម៉ូតអាវរាងស្ត្រី និងដាក់អាវក្នុងសំពត់ឬខោ
- សំពត់ខ្លី មានសាច់ក្រណាត់និងពណ៌ដូចអាវកាត់ស្រុងក្រោមជង្គង់ ផែកក្រោយ រូតខាងក្រោយ ឬខោម៉ូតដូចបុរស តែគ្មានហោប៉ៅក្រោយ។

គំរូសម្លៀកបំពាក់របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យនេះ។/.

**មាត្រា៥ .-**

មួករបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ជាមួកកាស្កេតធ្វើពីសាច់ក្រណាត់និងពណ៌ដូចសម្លៀកបំពាក់ ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស ទំហំកម្ពស់៧៨មិល្លីម៉ែត្រ ទទឹង៦៨មិល្លីម៉ែត។ នៅខាងក្រោមព្រះរាជសង្ហារនេះ មានកណ្តាប់វ័ណ្ឌប៉ានពណ៌បៃតង និងមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសចំកណ្តាលខាងមុខដល់ជើងមួកឬគ្មានតាមថ្នាក់នីមួយៗ។ នៅផ្នែកក្រោមកណ្តាប់វ័ណ្ឌប៉ានពណ៌បៃតងមានខ្សែធ្លាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែធ្លាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាសចំនួន២(ពីរ)គ្រាប់។ ក្បាំងមួកមានពណ៌ខ្មៅ ផ្នែកខាងមុខនៃក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសពណ៌មាសទម្រង់ស្លែងក្របីដល់ជើងមួក ឬពាក់កណ្តាលជើងមួក ឬគ្មានតាមថ្នាក់នីមួយៗ។ គែមរបស់ក្បាំងមួកមានវ័ណ្ឌទំហំ៥មិល្លីម៉ែត្រពណ៌មាសព័ទ្ធដល់ជើងមួកឬគ្មានតាមថ្នាក់នីមួយៗ។

មួកកាស្កេតនេះត្រូវបានកំណត់ជា ៥(ប្រាំ)ថ្នាក់ដូចខាងក្រោម៖

**១- ថ្នាក់ប្រធាននាយកដ្ឋាន**

ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្តាប់វ័ណ្ឌប៉ានពណ៌បៃតងមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសចំកណ្តាលខាងមុខដល់ជើងមួក។ នៅផ្នែកក្រោមប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសនេះមានខ្សែធ្លាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែធ្លាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាលនិងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាងប្រាំមួយទងពណ៌មាសទម្រង់ស្លែងក្របីចុងសងខាងដល់ជើងមួក និងគែមរបស់ក្បាំងមួកមានវណ្ឌទំហំ៥មិល្លីម៉ែត្រពណ៌មាសព័ទ្ធដល់ជើងមួក។

**២- ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីរ**

ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្តាប់វ័ណ្ឌប៉ានពណ៌បៃតងមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសចំកណ្តាលខាងមុខដល់ជើងមួក។ នៅផ្នែកក្រោមប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសនេះមានខ្សែធ្លាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែធ្លាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាងប្រាំមួយទងពណ៌មាសទម្រង់ស្លែងក្របីចុងសងខាងដល់ជើងមួក។

**៣- ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរ**

ផ្នែកខាងមុខខាងលើមានភ្ជាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្តាប់វ័ណ្ឌប៉ានពណ៌បៃតងមិនមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសទេ មានខ្សែធ្លាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែធ្លាក់វេញនេះមានភ្ជាប់ឡេវរូបព្រះរាជសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាងបួនទងពណ៌មាសទម្រង់ស្លែងក្របី។/.

**៤- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធានការិយាល័យ និងអនុប្រធានការិយាល័យនៃមន្ទីរ**

ផ្នែកខាងមុខខាងលើមានក្អាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្តាប់វ័ណ្ណប៉ានពណ៌បៃតងមិនមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសទេ មានខ្សែធ្នាក់វេញពណ៌មាស ហើយនៅចុងសងខាងខ្សែធ្នាក់វេញនេះមានក្អាប់ឡេវរូបព្រះរាជសង្ហារពណ៌មាស។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ផ្កាភ្ញីទេសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្ញីទេសម្ខាងពីរទងពណ៌មាសទម្រង់ស្នែងក្របី។

**៥- ថ្នាក់មន្ត្រី**

ផ្នែកខាងមុខខាងលើមានក្អាប់រូបព្រះរាជសង្ហារពណ៌មាស នៅលើកណ្តាប់វ័ណ្ណប៉ានពណ៌បៃតងមិនមានប៉ាក់ក្បាច់ផ្កាភ្ញីទេសពណ៌មាសទេ មានខ្សែធ្នាក់វេញពណ៌មាសហើយនៅចុងសងខាងខ្សែធ្នាក់វេញនេះមានក្អាប់ឡេវរូបព្រះរាជសង្ហារពណ៌មាស។ នៅលើជាយក្បាំងពណ៌ខ្មៅមានវណ្ឌទំហំ៥មិល្លីម៉ែត្រពណ៌មាសព័ទ្ធជុំជើងមួក។

គំរូមួករបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

ខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់ដូចខាងក្រោមៈ

**១- ចំពោះបុរស**

- ស្បែកជើងឃ្លុបកខ្លី ស្បែកពណ៌ខ្មៅ និងមានស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវាត់ពណ៌មាសទំហំទទឹង៣៨មិល្លីម៉ែត្រ និងបណ្តោយ៦៥មិល្លីម៉ែត្រដែលមាននិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មនៅចំកណ្តាលនៃក្បាលខ្សែក្រវាត់។

**២- ចំពោះស្ត្រី**

- ស្បែកជើងឃ្លុបកខ្លីមានកែងកម្ពស់៣០មិល្លីម៉ែត្រ ឬកែងរាបស្មើ ស្បែកពណ៌ខ្មៅ និងមានស្រោមជើងពណ៌ខ្មៅ
- ខ្សែក្រវាត់ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវាត់ពណ៌មាសទំហំទទឹង៣៣មិល្លីម៉ែត្រ និងបណ្តោយ៦៥មិល្លីម៉ែត្រ ដែលមាននិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មនៅចំកណ្តាលនៃក្បាលខ្សែក្រវាត់។

គំរូខ្សែក្រវាត់ ស្បែកជើង និងស្រោមជើងរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃ អនុក្រឹត្យនេះ។

## ជំពូកទី៣
## សញ្ញាសម្គាល់

**មាត្រា៧ .-**

សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចផ្នែកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់ដូចខាងក្រោម៖

**១- សញ្ញាសម្គាល់សម្រាប់ពាក់លើចុងកអាវទាំងសងខាង**

តួសញ្ញាសម្គាល់នេះធ្វើពីលោហធាតុដែលមានរាងមូលមានអង្កត់ផ្ចិត៣០មិល្លីម៉ែត្រ ដែលជានិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្ម។

**២- សញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ**

សញ្ញាសម្គាល់នេះ ជានិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្ម ដែលតួសញ្ញាសម្គាល់នេះត្រូវបានធ្វើពីសាច់ក្រណាត់ដោយមានលក្ខណៈកិនភាគដូចតទៅ៖

- មានអង្កត់ផ្ចិត៧០មិល្លីម៉ែត្រ សម្រាប់ដេរភ្ជាប់នៅដើមដៃអាវខាងស្តាំ ក្រោមថ្នេរស្មា៥០មិល្លីម៉ែត្រ ដោយកំណត់យកក្លីធ្វើជាចំណុចកណ្តាល
- ផ្ទៃខាងក្នុងមានកម្រងកួរស្រូវពោតនិងផ្កាកប្បាសអមសងខាងជារង្វង់ស្វែងក្របីពណ៌មាសហ៊ុមព័ទ្ធដោយបូរពណ៌ក្រហមលាយខៀវ ជាបីថ្នាក់ជួបគ្នាខាងចុង ដោយមានប្រាសាទកំពូលបីនៅចំកណ្តាល
- នៅគល់កួរស្រូវនិងផ្កាពោតមានកម្រងបូរពណ៌ទង់ជាតិច្នៃជាក្បាច់ដោយមានសរសេរអក្សរកាត់ "**នធនក**" ពណ៌ស តំណាងឱ្យនាយកដ្ឋាននីតិកម្មកសិកម្ម
- នៅក្រោមអក្សរកាត់មានស្លឹគ្រឿងចក្រពណ៌មាសតំណាងឱ្យការវិវឌ្ឍរីកចម្រើនរបស់វិស័យកសិឧស្សាហកម្ម
- នៅខាងលើអក្សរកាត់មានរាងអក្សរ A ពណ៌ពងមាន់ តំណាងឱ្យសំណង់សិល្បការ និងទ្វារទឹក
- ផ្ទៃក្នុងចំកណ្តាលមានរូបសញ្ញារោងចក្រពណ៌ពងមាន់កំពុងបញ្ចេញសកម្មភាពដែលតំណាងឱ្យភាពរីកចម្រើននៃវិស័យកសិកម្ម ផ្តល់វត្ថុធាតុដើមឱ្យរោងចក្រគ្រប់ពេល ដើម្បីផលិតចេញនូវផលិតផលបម្រើសង្គម
- ផ្ទៃក្នុងផ្នែកខាងក្រោម មានវាលស្រែពណ៌បៃតងខ្ចី មានប្រព័ន្ធស្រោចស្រពទឹក តំណាងឱ្យភាពរីកចម្រើននៃវិស័យកសិកម្មលើដំណាំគ្រប់ប្រភេទ
- ផ្ទៃក្នុងផ្នែកខាងក្រោមនៅលើវាលស្រែមានសៀវភៅផ្ទៃពណ៌សគែមសងខាងពណ៌ក្រហមដែលមានចារឹកអក្សរ "**ច្បាប់កសិកម្ម**" នៅសងខាង និងមានខ្សែបន្ទាត់ចំនួន១០ ពណ៌ខៀវកាត់ទទឹង ដែលតំណាងឱ្យបណ្តាលិខិតបទដ្ឋានគតិយុត្តដែលទាក់ទងនឹងវិស័យកសិកម្ម
- ផ្ទៃក្នុងផ្នែកខាងលើពណ៌ផ្ទៃមេឃ មានប្រាំកាំ៖ កាំទី១ រូបត្រាក់ទ័រ កាំទី២ រូបគោ ជ្រូក មាន់ កាំទី៣ រូបកែវស្ទង់ កាំទី៤ រូបត្រី កាំទី៥ រូបដើមឈើ ដែលតំណាងឱ្យភាពរីកចម្រើនលើវិស័យគ្រឿងយន្តកសិកម្ម ចិញ្ចឹមសត្វ ការសិក្សាស្រាវជ្រាវបច្ចេកទេស វិទ្យាសាស្ត្រ និងធនធានធម្មជាតិ។

៣- សញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងឆ្វេង

សញ្ញាសម្គាល់នេះ ជាសញ្ញាសម្គាល់ដែលមាននិមិត្តសញ្ញាជាអក្សរថា **"អធិការកិច្ចថ្នាំកសិកម្ម និងជីកសិកម្ម"** ដែលប៉ាក់សម្រាប់ដេរភ្ជាប់នៅលើដើមដៃអាវខាងឆ្វេងមានប្រវែង៥០មិល្លីម៉ែត្រពីថ្នេរស្មាអាវ ក្រណាត់ប៉ាក់កម្ពស់២២មិល្លីម៉ែត្រ និងមានបណ្តោយប្រវែង១០៥មិល្លីម៉ែត្រ។

៤- សញ្ញាសម្គាល់ឈ្មោះមន្ត្រីសម្រាប់ពាក់លើគម្របហោប៉ៅអាវស្តាំ

តួសញ្ញាសម្គាល់នេះធ្វើពីលោហធាតុ មានផ្ទៃពណ៌បៃតង គួសបន្ទាត់ពណ៌មាសជុំវិញតួអក្សរពណ៌ស មានបណ្តោយ១០០មិល្លីម៉ែត្រនិងទទឹង២០មិល្លីម៉ែត្រ ដែលត្រូវដាក់នៅលើហោប៉ៅអាវខាងស្តាំ។ តួសញ្ញាសម្គាល់ត្រូវបានចែកចេញជាពីរផ្នែក ផ្នែកខាងស្តាំមានបណ្តោយ២៥មិល្លីម៉ែត្រ នៅចំកណ្តាលមាននិមិត្តសញ្ញារបស់**"នាយកដ្ឋាននីតិកម្មកសិកម្ម"** មានអង្កត់ផ្ចិត១៥មិល្លីម៉ែត្រនៅក្រោមសញ្ញាសម្គាល់នេះ មានអក្សរកាត់ **"នគក ឬ មកសក"**ពណ៌ស។ ផ្នែកខាងឆ្វេងមានបណ្តោយ៧៥មិល្លីម៉ែត្រ មានអក្សរពីរជួរខណ្ឌដោយឆ្នូតពណ៌មាស ជួរទី១សរសេរឈ្មោះមន្ត្រីសាមីជាអក្សរខ្មែរ មានកម្ពស់អក្សរ៥មិល្លីម៉ែត្រ និងជួរទី២សរសេរពីតួនាទីមន្ត្រីសាមីជាអក្សរខ្មែរមានកម្ពស់អក្សរ៣មិល្លីម៉ែត្រ។

៥- សញ្ញាសម្គាល់សម្រាប់ព្យួរលើឡេវគម្របហោប៉ៅអាវស្តាំ

តួសញ្ញាសម្គាល់នេះធ្វើពីលោហធាតុរាងសំប៉ែតមាននិមិត្តសញ្ញារបស់ **"នាយកដ្ឋាននីតិកម្មកសិកម្ម"** មានអង្កត់ផ្ចិត៤៥មិល្លីម៉ែត្រ ភ្ជាប់ដោយបន្ទះស្បែកសម្រាប់ព្យួរនៅហោប៉ៅអាវខាងស្តាំ។

គំរូសញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## សញ្ញាសក្តិ

**មាត្រា៨ .-**

សញ្ញាសក្តិសម្រាប់ពាក់លើស្មាអាវទាំងសងខាងរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មធ្វើឡើងពីលោហធាតុ ដែលមានរាងទ្រវែងស្ទួចប្រវែង១៣២មិល្លីម៉ែត្រ មានទំហំខាងគល់ប្រវែង៥៧មិល្លីម៉ែត្រ ខាងចុងប្រវែង៤៥មិល្លីម៉ែត្រ និងមានរាងកោងជាមុំទាល ដោយត្រូវបានបែងចែកជា៥(ប្រាំ)ថ្នាក់ មានដូចខាងក្រោម៖

**១- ថ្នាក់ប្រធាននាយកដ្ឋាន**

សញ្ញាសក្តិនេះមានផ្ទៃពណ៌បៃតងចាស់ មានស៊ុមធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញកម្រាស់៦មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសគល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ក្នុងស៊ុមផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសទំហំអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ នៅពីក្រោមឡេវព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រមាននិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មទំហំអង្កត់ផ្ចិតប្រវែង២៥មិល្លីម៉ែត្រ នៅពីក្រោមនិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសតន្ទួយហង្សពណ៌មាសកម្ពស់១៤មិល្លីម៉ែត្រមានបណ្តោយជាប់ស៊ុមនៅពីក្រោមចម្លាក់ក្បាច់អង្គរភ្ញីទេសតន្ទួយហង្សពណ៌មាសនេះ មានខ្សែសយពណ៌មាស២ជាន់ចំនួន២ទំហំ១មិល្លីម៉ែត្រ និងមានបណ្តោយជាប់ស៊ុមនៅចន្លោះខ្សែសយទាំងពីរមានចារឹកអក្សរ **"នីតិកម្មកសិកម្ម"** ពណ៌មាស។

**២- ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីរ**

សញ្ញាសក្តិនេះមានផ្ទៃពណ៌បៃតងចាស់ មានស៊ុមធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញកម្រាស់៦មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសគល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ក្នុងស៊ុមផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសទំហំអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ នៅពីក្រោមឡេវព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មទំហំអង្កត់ផ្ចិតប្រវែង២៥មិល្លីម៉ែត្រ នៅពីក្រោមនិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសកម្ពស់១៤មិល្លីម៉ែត្រ មានបណ្តោយជាប់ស៊ុមនៅពីក្រោមចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសនេះមានខ្សែសយពណ៌មាស១ជាន់ចំនួន២ទំហំ១,៥មិល្លីម៉ែត្រ និងមានបណ្តោយជាប់ស៊ុមនៅចន្លោះខ្សែសយទាំងពីរមានចារឹកអក្សរ"**នីតិកម្មកសិកម្ម**" ពណ៌មាស។

**៣- ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរ**

សញ្ញាសក្តិនេះមានផ្ទៃពណ៌បៃតងចាស់ មានស៊ុមធ្មេញត្រីពណ៌មាសព័ទ្ធជុំវិញកម្រាស់ ៥មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេស គល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ក្នុងស៊ុមផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសទំហំអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ នៅពីក្រោមឡេវព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មទំហំអង្កត់ផ្ចិតប្រវែង២៥មិល្លីម៉ែត្រ នៅពីក្រោមនិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសកម្ពស់១៤មិល្លីម៉ែត្រ មានបណ្តោយជាប់ស៊ុមនៅពីក្រោមចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសនេះមានខ្សែសយពណ៌ប្រាក់២ជាន់ចំនួន២ទំហំ១មិល្លីម៉ែត្រ និងមានបណ្តោយជាប់ស៊ុមនៅចន្លោះខ្សែសយទាំងពីរមានចារឹកអក្សរ" **នីតិកម្មកសិកម្ម**" ពណ៌មាស។

**៤- ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធានការិយាល័យ និងអនុប្រធានការិយាល័យនៃមន្ទីរ**

សញ្ញាសក្តិនេះមានផ្ទៃពណ៌បៃតងចាស់ មានស៊ុមធ្មេញត្រីពណ៌មាសព័ទ្ធជុំវិញកម្រាស់៥មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសគល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ក្នុងស៊ុមផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសទំហំអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ នៅពីក្រោមឡេវព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មទំហំអង្កត់ផ្ចិតប្រវែង២៥មិល្លីម៉ែត្រ នៅពីក្រោមនិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសកម្ពស់១៤មិល្លីម៉ែត្រ មានបណ្តោយជាប់ស៊ុមនៅពីក្រោមចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសនេះមានខ្សែសយពណ៌ប្រាក់១ជាន់ចំនួន២ទំហំ១,៥មិល្លីម៉ែត្រ និងមានបណ្តោយជាប់ស៊ុមនៅចន្លោះខ្សែសយទាំងពីរមានចារឹកអក្សរ "**នីតិកម្មកសិកម្ម**" ពណ៌មាស។

**៥- ថ្នាក់មន្ត្រី**

សញ្ញាសក្តិនេះមានផ្ទៃពណ៌បៃតងចាស់ មានស៊ុមធ្មេញត្រីពណ៌មាសព័ទ្ធជុំវិញកម្រាស់ ៥មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសគល់ស៊ុមផ្នែកខាងក្រោមមានទំហំ១២មិល្លីម៉ែត្រ។ ក្នុងស៊ុមផ្នែកខាងលើមានឡេវរូបព្រះរាជសង្ហារពណ៌មាសទំហំអង្កត់ផ្ចិតប្រវែង១៦មិល្លីម៉ែត្រ នៅពីក្រោមឡេវព្រះរាជសង្ហារប្រវែង២០មិល្លីម៉ែត្រ មាននិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មទំហំអង្កត់ផ្ចិតប្រវែង២៥មិល្លីម៉ែត្រ នៅពីក្រោមនិមិត្តសញ្ញារបស់នាយកដ្ឋាននីតិកម្មកសិកម្មប្រវែង២០មិល្លីម៉ែត្រ មានចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌

មាសកម្ពស់១៤មិល្លីម៉ែត្រ មានបណ្តោយជាប់ស៊ុម នៅពីក្រោមចម្លាក់ក្បាច់អង្គរភ្ញីទេសកន្ទុយហង្សពណ៌មាសនេះមានចារឹកអក្សរ "**នីតិកម្មកសិកម្ម**" ពណ៌មាស។

គំរូសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## ការផ្តល់និងប្រើឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ

**មាត្រា៩ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវបានផ្តល់ជូនមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម នៃនាយកដ្ឋាននីតិកម្មកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងម្នាក់ចំនួន២(ពីរ)សម្រាប់ ដើម្បីប្រើក្នុងរយៈពេល១(មួយ)ឆ្នាំ។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវប្រើថវិកាជាតិ និងមានលក្ខណៈសមស្របទៅនឹងទំហំនៃថវិកាជាតិប្រចាំឆ្នាំដែលបានផ្តល់ភោជន៍ជូន។

**មាត្រា១០ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវបានប្រើដូចមាននៅក្នុងឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យនេះ។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា១១ .-**

ជនណាដែលបានក្លែងឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ ឬក្លែងបន្លំខ្លួនដោយស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា១២ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម ដែលកំពុងប្រើសព្វថ្ងៃត្រូវបន្តរហូតដល់មានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិថ្មីមកជំនួស។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃអនុក្រឹត្យ លេខ...១៣.....អនក្រ.បក ចុះថ្ងៃទី..០៤..ខែ..កុម្ភៈ...ឆ្នាំ២០១៧
"ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម"

## គំរូឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

### ១. គំរូសម្លៀកបំពាក់

#### ១.១. អាវថ្នាក់ដឹកនាំនាយកដ្ឋាន មន្ទីរ និងការិយាល័យ

ក.ចំពោះបុរស



ខាងមុខ



ខាងក្រោយ

ខ.ចំពោះស្ត្រី



ខាងមុខ



ខាងក្រោយ

១.២. ថ្នាក់មន្ត្រី



ខាងមុខ



ខាងក្រោយ

១.៣. ខោបុរសនិងសំពត់ស្ត្រី





ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យ លេខ...១៣...អនក្រ.បក ចុះថ្ងៃទី.០៧...ខែ..កុម្ភៈ...ឆ្នាំ២០១៧
ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

## ២. គំរូមួក

| | |
|---|---|
|  | ថ្នាក់ប្រធាននាយកដ្ឋាន |
|  | ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីរ |
|  | ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិង ថ្នាក់អនុប្រធានមន្ទីរ |
|  | - ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល<br>- ប្រធានការិយាល័យ និងអនុប្រធាន ការិយាល័យ នៃមន្ទីរ |
|  | ថ្នាក់មន្ត្រី |

ឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យ លេខ....១៣....អនក្រ.បក ចុះថ្ងៃទី...០៧.ខែ..កុម្ភៈ....ឆ្នាំ២០១៧
ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

៣. គំរូខ្សែក្រវាត់ ស្បែកជើង និងស្រោមជើង

| | |
|---|---|
|  | ខ្សែក្រវាត់ចំពោះបុរស |
|  | ខ្សែក្រវាត់ចំពោះស្ត្រី |
|  | ស្បែកជើងចំពោះបុរស |
|  | ស្បែកជើងចំពោះស្ត្រី |
|  | ស្រោមជើង |

ឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យ លេខ...១៣.....អនក្រ.បក ចុះថ្ងៃទី...០៧...ខែ...កុម្ភៈ...ឆ្នាំ២០១៧
"ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម"

## គំរូសញ្ញាសម្គាល់

| | |
|---|---|
|  | សញ្ញាសម្គាល់សម្រាប់ពាក់លើចុងករអាវទាំងសងខាង |
|  | សញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងស្តាំ |
|  | សញ្ញាសម្គាល់សម្រាប់ដេរភ្ជាប់លើដើមដៃអាវខាងឆ្វេង |
|  | សញ្ញាសម្គាល់ឈ្មោះមន្ត្រីសម្រាប់ពាក់លើគម្របហោប៉ៅអាវស្តាំ |
|  | សញ្ញាសម្គាល់សម្រាប់ព្យួរលើខ្សែគម្របហោប៉ៅអាវស្តាំ |

ឧបសម្ព័ន្ធទី៥នៃអនុក្រឹត្យ លេខ...១៣....អនក្រ.បក ចុះថ្ងៃទី០២...ខែ.កុម្ភៈ....ឆ្នាំ២០១៧
"ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម"

## គំរូសញ្ញាសក្តិ

១. សញ្ញាសក្តិថ្នាក់ប្រធាននាយកដ្ឋាន



## ២. សញ្ញាសក្តិថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីរ



### ៣. សញ្ញាសក្តិថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរ



## ៤. សញ្ញាសក្តិថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាល ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ



៥. សញ្ញាសក្តិថ្នាក់មន្ត្រី





x

ឧបសម្ព័ន្ធទី៦នៃអនុក្រឹត្យ លេខ...១៣......អនក្រ.បក ចុះថ្ងៃទី...១៤...ខែ...កុម្ភៈ...ឆ្នាំ២០១៧
"ស្តីពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម"

# ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម

